អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/២៨៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០២ រូប :

១- ឯកឧត្តម **សូ សឿន** មានឋានៈស្មើ **អគ្គនាយក**

២- ឯកឧត្តម **លឹម អែល ឧប៉ាដូ** មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣ខស.១៤០២ ២៥២

លេខ: ... ស.ណ
សំណៅ...ចែកផ្សាយ
រាជធានីភ្នំពេញ ... ខែ ៣ ឆ្នាំ២០១៤
...រាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/២៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឡៅ ម៉ុនឡុង** ជាជំនួយការឯកឧត្តម **អ៊ុច គីមអន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរល.១៤០២ ២៥៣

**លេខ: [illegible] ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ [illegible] ខែ មីនា ឆ្នាំ២០១៤**
**[illegible] រាជរដ្ឋាភិបាល**

**ឆេយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៤/២៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងឯកឧត្តម **លុយ ដាវីត** ជាទីប្រឹក្សា និងនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចាស.១៤០២ ២៥៤

លេខៈ [illegible] ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.៣២៣,៣៣ ហិកតា នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ចេញពីដីតំបន់ការពារទេសភាពបន្ទាយឆ្មារ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈបានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៦ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១៦៩៧ ខជ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៥៤៧ ខជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ១.៣២៣,៣៣ ហិកតា ចេញពីដីតំបន់ការពារទេសភាពបន្ទាយឆ្មារ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៦ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែល ទំហំ ១.១០៤,១១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២១៩,២២ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិតាមាន់សែនជ័យ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាមាន់សែនជ័យ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ១.៥៤៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.៥៤៥ ក្បាលដី ជូនប្រជាពលរដ្ឋ ១.៣៩៩ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (ដីមណ្ឌលសុខភាព ០១ ក្បាលដី ដីសាលារៀន ០១ ក្បាលដី និងដីផ្សាររបស់ស្រុក ០១ ក្បាលដី) ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

រាជរដ្ឋាភិបាល
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២២៣,៧៨៥៨ហិកតា នៅស្រុកឈូក ខេត្តកំពត ក្នុងនោះ កាត់ចេញពី (១) ដីឧទ្យានជាតិព្រះមុនីវង្សបូកគោ និង(២) ដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ៣១៦ល.ស ចុះថ្ងៃទី ២៨ ខែមិថុនាឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ **២២៣,៧៨៥៨ ហិកតា ក្នុងនោះ** (១) ទំហំ **១៨៣.៨៣៧៩ ហិកតា** កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និង (២) ទំហំ **៣៩.៩៤៧៩ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋទំហំ **២០១.៥១៧៩ ហិកតា** សម្រាប់ប្រទានកម្មដីជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ **២២,២៦៧៩ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិតេជោក្បាលដំរី ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូកខេត្តកំពត** តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន **២៥៥ គ្រួសារ** ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង **នៅភូមិតេជោក្បាលដំរី ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូកខេត្តកំពត** ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦១៤,០២៧៣ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៥ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ៣១៤ ល.ស ចុះថ្ងៃទី ២៤ ខែមិថុនាឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៦១៤,០២៧៣ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៥ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៥៦៤,៩៥២៤ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៤៩,០៧៤៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិមាត់ពាម ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៦២៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិមាត់ពាម ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូខេត្តកំពត ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២០៣,៤៣០៧ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ក្នុងនោះ កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០១ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៧ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ៣៨៩ ល.ស ចុះថ្ងៃទី ២១ខែតុលា ឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ **២០៣,៤៣០៧ ហិកតា** ក្នុងនោះ (១) ទំហំ **១២៨,៣៩០៧ ហិកតា** កាត់ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៣៧ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ (២) ទំហំ **៧៥,០៤០០ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ **១៨៤,១១៥៤ ហិកតា** សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ **១៩,៣១៥៣ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិស្នំប្រាំពីរ ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ** ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន **២០១ គ្រួសារ** ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិស្នំប្រាំពីរ ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត ។/.

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៣.២៣៣,១៦ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៤២ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១៦៩៥ ឧជ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៣៧៥ ឧជ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ៣.២៣៣,១៦ ហិកតា ក្នុងនោះ (១) ទំហំ ១៤៧,៨០ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២៤២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៤ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង (២) ទំហំ ៣.០៨៥,៣៦ ហិកតា កាត់ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ សម្រាប់ធ្វើប្រទានកម្ម ទំហំ ២.៥២០,២១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះ ជាក់ស្តែង និងទំហំ ៧១២,៩៥ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅនៅភូមិតេជោ អភិវឌ្ឍន៍ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងដែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិ

ជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតេជោអភិវឌ្ឍន៍ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៩៦៥ ក្បាលដី ជូនប្រជាពលរដ្ឋ ៦៦៧ គ្រួសារ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរ-មានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ ៖ ១

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ៣២៣៣.១៦ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងកាត់ចេញពីដីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនតៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិលើក្បាលដី



ឧបសម្ព័ន្ធ(២)

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..៥៥..អនក្រ.បក..ចុះថ្ងៃទី...០៣.....ខែ..មីនា....ឆ្នាំ ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ៣២៣៣.១៦ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនតៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិលើក្បាលដី**

**តារាងនិយាមការព្រំដី សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ**

Coordinate System UTM, Zone 48N, Datum WGS 1984

| ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point |
|---|---|---|---|---|---|---|---|---|
| 1 | 417808 | 1566001 | 49 | 423620 | 1561457 | 97 | 415575 | 1562248 |
| 2 | 417862 | 1566000 | 50 | 423620 | 1561457 | 98 | 415590 | 1562321 |
| 3 | 417929 | 1566014 | 51 | 423599 | 1560961 | 99 | 415766 | 1562322 |
| 4 | 418157 | 1565997 | 52 | 423599 | 1560961 | 100 | 415808 | 1562376 |
| 5 | 418234 | 1566000 | 53 | 423996 | 1560995 | 101 | 415936 | 1562406 |
| 6 | 418247 | 1565893 | 54 | 423998 | 1560332 | 102 | 415845 | 1562260 |
| 7 | 418341 | 1565825 | 55 | 423998 | 1560331 | 103 | 416147 | 1562337 |
| 8 | 418448 | 1565794 | 56 | 415595 | 1560338 | 104 | 416087 | 1562041 |
| 9 | 418667 | 1565769 | 57 | 415567 | 1560357 | 105 | 416154 | 1562038 |
| 10 | 418672 | 1565860 | 58 | 415474 | 1560339 | 106 | 416176 | 1562022 |
| 11 | 418805 | 1565885 | 59 | 415430 | 1560410 | 107 | 416204 | 1562008 |
| 12 | 418812 | 1565941 | 60 | 415209 | 1560363 | 108 | 416256 | 1562016 |
| 13 | 418902 | 1565935 | 61 | 415193 | 1560409 | 109 | 417011 | 1562286 |
| 14 | 419071 | 1565864 | 62 | 415098 | 1560638 | 110 | 417576 | 1562285 |
| 15 | 419167 | 1565787 | 63 | 414952 | 1560687 | 111 | 417576 | 1562599 |
| 16 | 419451 | 1565737 | 64 | 415024 | 1560730 | 112 | 417478 | 1562809 |
| 17 | 419630 | 1565768 | 65 | 415021 | 1560846 | 113 | 417551 | 1562929 |
| 18 | 419695 | 1565644 | 66 | 415130 | 1560924 | 114 | 417554 | 1563191 |
| 19 | 419858 | 1565654 | 67 | 415146 | 1560944 | 115 | 417520 | 1563199 |
| 20 | 419872 | 1565620 | 68 | 415056 | 1561018 | 116 | 417562 | 1563459 |
| 21 | 419861 | 1565513 | 69 | 414918 | 1561094 | 117 | 417560 | 1563472 |
| 22 | 419925 | 1565468 | 70 | 414936 | 1561112 | 118 | 417557 | 1563727 |
| 23 | 420009 | 1565523 | 71 | 415015 | 1561125 | 119 | 417544 | 1563729 |
| 24 | 420013 | 1565538 | 72 | 415011 | 1561269 | 120 | 417539 | 1563829 |
| 25 | 420043 | 1565532 | 73 | 415091 | 1561291 | 121 | 417549 | 1563906 |
| 26 | 420048 | 1565546 | 74 | 415094 | 1561329 | 122 | 417565 | 1563966 |
| 27 | 420106 | 1565583 | 75 | 415087 | 1561422 | 123 | 417600 | 1564026 |
| 28 | 420143 | 1565605 | 76 | 415049 | 1561494 | 124 | 417627 | 1564289 |
| 29 | 420504 | 1565495 | 77 | 415027 | 1561572 | 125 | 417504 | 1564566 |
| 30 | 420512 | 1565516 | 78 | 415056 | 1561610 | 126 | 417510 | 1564557 |
| 31 | 420506 | 1565609 | 79 | 415007 | 1561743 | 127 | 417620 | 1564704 |
| 32 | 420513 | 1565633 | 80 | 414938 | 1561774 | 128 | 417699 | 1564670 |
| 33 | 420668 | 1565727 | 81 | 414912 | 1561777 | 129 | 417715 | 1564964 |
| 34 | 422368 | 1565698 | 82 | 414864 | 1561764 | 130 | 417621 | 1564973 |
| 35 | 422370 | 1561323 | 83 | 414854 | 1561817 | 131 | 417681 | 1565065 |
| 36 | 422987 | 1561250 | 84 | 414823 | 1561850 | 132 | 417605 | 1565168 |
| 37 | 422997 | 1561312 | 85 | 414844 | 1561954 | 133 | 417606 | 1565275 |
| 38 | 423030 | 1561319 | 86 | 414852 | 1562014 | 134 | 417587 | 1565286 |
| 39 | 423082 | 1561340 | 87 | 414849 | 1562108 | 135 | 417584 | 1565508 |
| 40 | 423113 | 1561342 | 88 | 414761 | 1562159 | 136 | 417709 | 1565636 |
| 41 | 423144 | 1561346 | 89 | 414759 | 1562200 | 137 | 417536 | 1565593 |
| 42 | 423172 | 1561349 | 90 | 414762 | 1562223 | 138 | 417581 | 1565737 |
| 43 | 423234 | 1561354 | 91 | 414742 | 1562294 | 139 | 417514 | 1565842 |
| 44 | 423295 | 1561360 | 92 | 414961 | 1562371 | 140 | 417537 | 1565879 |
| 45 | 423319 | 1561365 | 93 | 415014 | 1562238 | 141 | 417587 | 1565928 |
| 46 | 423370 | 1561361 | 94 | 415050 | 1562243 | 142 | 417628 | 1566045 |
| 47 | 423433 | 1561378 | 95 | 415279 | 1562326 | 143 | 417812 | 1566046 |
| 48 | 423512 | 1561397 | 96 | 415408 | 1562307 | 144 | 417808 | 1566001 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រាក់ឧបត្ថម្ភជូនប្រធានការិយាល័យប្រជាពលរដ្ឋ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧២អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ២១៤អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចលេខ ១២ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រធានការិយាល័យប្រជាពលរដ្ឋ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ជាថ្មីនូវកម្រិតនៃប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រធានការិយាល័យ ប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើប្រធានការិយាល័យប្រជាពលរដ្ឋ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ។

## ជំពូកទី២
## ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ

**មាត្រា៤.-**

ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតការិយាល័យច្រកចេញចូលតែមួយ ៥០០ ០០០ (ហាសិបម៉ឺន) រៀលស្មើនឹងប្រាក់ ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ។

**មាត្រា៥.-**

ការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រធានការិយាល័យប្រជាពលរដ្ឋដូចបានកំណត់ក្នុងមាត្រា៤ ខាងលើ ត្រូវអនុវត្តចំពោះប្រធានការិយាល័យប្រជាពលរដ្ឋដែលស្ថិតនៅក្នុងមុខតំណែងតែប៉ុណ្ណោះ។

ការផ្តល់ប្រាក់ឧបត្ថម្ភនេះ ត្រូវគ្រោងនិងបើកផ្តល់នៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដោយគិតពីខែមេសា ឆ្នាំ២០១៤តទៅ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៦.-**

អនុក្រឹត្យលេខ២៣អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភ ចំពោះប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលស្រុកសាកល្បង ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ត្រូវទុកជានិរាករណ៍។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កកទ្រព្យសម្បត្តិរបស់ភេរវករនិងអង្គការនានា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៥៦អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណង បង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពភេរវកម្មនិងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតយន្តការ និងនីតិវិធីបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់ភេរវករ និងអង្គការនានាស្របតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លេខ ១២៦៧ និងលេខ ១៣៧៣ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តយន្តការ និងនីតិវិធីបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់ភេរវករ និងអង្គការនានា ស្របតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងស្របតាមផ្នែកទី២ ជំពូកទី១១ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម និងបទប្បញ្ញត្តិ ដែលមានចែងនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី២
## វិធានការចំពោះភេរវករ និងអង្គការនានាដែលមានក្នុងបញ្ជីអង្គការសហប្រជាជាតិ

**មាត្រា៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនដោយគ្មានបង្អង់ទៅក្រសួងយុត្តិធម៌ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នូវបញ្ជីដាក់ឈ្មោះឬដកឈ្មោះចេញពីបញ្ជីភេរវករ ឬ អង្គការនានា តាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ដែលត្រូវទទួលទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ ឬការហាមឃាត់ផ្សេងទៀត។

នៅពេលទទួលបានសេចក្តីជូនដំណឹងអំពីការកំណត់របស់អង្គការសហប្រជាជាតិ ក្រសួងយុត្តិធម៌ត្រូវបញ្ជូនភ្លាមនូវបញ្ជីឈ្មោះ ឬការដកចេញពីបញ្ជីឈ្មោះភេរវករឬអង្គការនានាទៅតុលាការ ដើម្បីចេញដីកាបង្កក ឬដកចេញដីកាបង្កក និងត្រូវបោះផ្សាយនៅក្នុងគេហទំព័សាធារណៈរបស់ក្រសួងយុត្តិធម៌។ តុលាការត្រូវចាត់ការភ្លាមដើម្បីចេញដីកាបង្កក ស្របតាមខ្លឹមសារនៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧។ ទ្រព្យសម្បត្តិនិងមូលនិធិដែលត្រូវបានបង្កករួចហើយតាមដីការបស់តុលាការ ត្រូវបានរក្សាទុកដោយគ្មានពេលកំណត់រហូតដល់ដីកាបង្កកនោះត្រូវបានដកចេញស្របតាម មាត្រា៧ នៃអនុក្រឹត្យនេះ។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវបញ្ជូនដោយគ្មានបង្អង់នូវបញ្ជីដាក់ឈ្មោះ ឬដកឈ្មោះចេញពីបញ្ជីភេរវករឬអង្គការនានា ទៅឲ្យបុគ្គលរាយការណ៍ដែលស្ថិតក្រោមចំណុះច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយត្រូវបោះផ្សាយបញ្ជីទាំងនេះនៅក្នុងគេហទំព័រសាធារណៈ

របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

បុគ្គលរាយការណ៍និងបុគ្គលផ្សេងទៀត ដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិនិងមូលនិធិដទៃទៀត ត្រូវបង្កកទ្រព្យសម្បត្តិនិងមូលនិធិទាំងនោះ ដោយគ្មានបង្អង់ បន្ទាប់ពីទទួលបានដីកាពីតុលាការ។

ការបង្កកទ្រព្យសម្បត្តិនិងមូលនិធិតាមដីការបស់តុលាការ មិនមានរយៈពេលកំណត់ និងត្រូវគ្រប ដណ្តប់លើ ៖

(ក) ទ្រព្យសម្បត្តិនិងមូលនិធិដែលជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងទាំងមូលឬរួមគ្នា ដោយផ្ទាល់ ឬដោយប្រយោល ដោយបុគ្គលដែលត្រូវបានកំណត់ក្នុងបញ្ជីភេរវករបុគ្គលដែលផ្តល់ហិរញ្ញប្បទានចំពោះភេរវករ ឬអង្គការភេរវកម្ម និង

(ខ) ទ្រព្យសម្បត្តិនិងមូលនិធិដែលទទួលបាន ឬកើតឡើងពីទ្រព្យសម្បត្តិនិងមូលនិធិ ដែលជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ដោយបុគ្គលដែលត្រូវបានកំណត់ក្នុងបញ្ជីភេរវករ បុគ្គលដែលផ្តល់ហិរញ្ញប្បទានចំពោះភេរវករឬអង្គការភេរវកម្ម។

បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញនូវឯកសារកត់ត្រារបស់ខ្លួនដោយគ្មានបង្អង់ ដើម្បីកំណត់ថាទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលដែលបានកំណត់ក្នុងបញ្ជីត្រូវបានបង្កកដោយគ្មានបង្អង់ ឬកំពុងត្រូវបានរក្សាទុក។

**មាត្រា៥.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវផ្តល់របាយការណ៍ទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ អំពីការបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គល ដែលបានកំណត់ក្នុងបញ្ជី បន្ទាប់ពីការសម្រេចជាស្ថាពររបស់តុលាការ និងការជូនព័ត៌មានពីក្រសួងយុត្តិធម៌។

**មាត្រា៦.-**

បន្ទាប់ពីបានទទួលសំណើរបស់ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលខុសត្រូវក្នុងការផ្តួចផ្តើមលើកសំណើសុំកំណត់បុគ្គលឬអង្គការ ដែលជាមុខសញ្ញាកំណត់ដោយសេចក្តីសម្រេចចិត្តលេខ១២៦៧ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ទៅគណៈកម្មាធិការទណ្ឌកម្មអង្គការសហប្រជាជាតិ។

**មាត្រា៧.-**

បុគ្គលឬអង្គការណាដែលទទួលរងផលប៉ះពាល់ដោយដីកាបង្កកនេះអាចដាក់ពាក្យបណ្តឹងសុំដកឈ្មោះចេញពីបញ្ជី១២៦៧ ទៅគណៈកម្មាធិការទណ្ឌកម្ម ឬទៅការិយាល័យទំនាក់ទំនង ឬទៅការិយាល័យស៊ើបអង្កេតពាក្យបណ្តឹងរបស់អង្គការសហប្រជាជាតិ ដើម្បីពិនិត្យសេចក្តីសម្រេចចិត្តនេះឡើងវិញ។

នៅពេលអង្គការសហប្រជាជាតិដកឈ្មោះបុគ្គលឬអង្គការដែលបានកំណត់ចេញពីបញ្ជី១២៦៧រួចហើយ តុលាការត្រូវដកដីកាបង្កកមកវិញ ដោយគ្មានបង្អង់។

**មាត្រា៨.-**

ដីកាបង្កករបស់តុលាការដែលបានកំណត់នៅក្នុងមាត្រា៤ មិនអនុវត្តចំពោះ[illegible] នៃទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កក ដែលគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការ[illegible]

បានកំណត់ថាចាំបាច់សម្រាប់៖

(ក) ចំណាយមូលដ្ឋាន រួមមានការទូទាត់ថ្លៃម្ហូបអាហារ ការជួល ឬសងបំណុលការព្យាបាលជំងឺនិងថ្នាំពេទ្យ ពន្ធដារ បុព្វលាភធានារ៉ាប់រងនិងចំណាយទឹកភ្លើង ឬចំណាយថ្លៃឈ្នួលវិជ្ជាជីវៈសមស្របនិងសំណងទូទាត់ចំណាយ ដែលទាក់ទងនឹងសេវាផ្លូវច្បាប់ ឬថ្លៃឈ្នួល ឬថ្លៃសេវាកាន់កាប់ ឬការថែរក្សាជាប្រចាំនូវទ្រព្យសម្បត្តិឬមូលនិធិ ដែលត្រូវបានបង្កក បន្ទាប់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជូនដំណឹងទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិសុំការអនុញ្ញាតប្រើប្រាស់ទ្រព្យសម្បត្តិឬមូលនិធិនោះ ហើយពុំមានការឆ្លើយតបពីគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីបានជូនដំណឹង ឬ

(ខ) ចំណាយពិសេស នៅពេលដែលគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិបានអនុម័ត បន្ទាប់ពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានជូនដំណឹងទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិសុំការអនុញ្ញាតប្រើប្រាស់ទ្រព្យសម្បត្តិឬមូលនិធិនោះ ឬនៅពេលពុំមានការឆ្លើយតបពីគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីបានជូនដំណឹង។

## ជំពូកទី៣
## វិធានការចំពោះភេរវករនិងអង្គការនានាក្នុងប្រទេស

**មាត្រា៩ .-**

បន្ទាប់ពីទទួលសំណើរបស់គតិយភាគី តាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬផ្អែកលើព័ត៌មានក្នុងប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង សម្គាល់អត្តសញ្ញាណនិងវាយតម្លៃបុគ្គល ដើម្បីបញ្ចូលឈ្មោះក្នុងបញ្ជី ឬដកឈ្មោះចេញពីបញ្ជី។

បញ្ជីនេះត្រូវបានបង្កើតឡើង ប្រសិនបើតុលាការពិនិត្យឃើញថាមានមូលហេតុសមហេតុផលនឹងសង្ស័យថា ៖

(ក) បុគ្គលនោះបានអនុវត្ត ឬប៉ុនប៉ងអនុវត្ត ឬចូលរួម ឬសម្រួលដល់សកម្មភាពភេរវកម្ម ឬ

(ខ) អង្គភាពនោះដែលត្រូវបានកាន់កាប់ ឬត្រួតពិនិត្យ ដោយផ្ទាល់ ឬដោយប្រយោល ដោយភេរវករ បុគ្គល ឬអង្គការដែលមានឈ្មោះក្នុងបញ្ជី ឬ

(គ) បុគ្គលដែលកំពុងធ្វើសកម្មភាពជំនួស តាមបញ្ជា ឬមានទំនាក់ទំនងជាមួយបុគ្គល ឬអង្គការដូចមានចែងក្នុងកថាខណ្ឌនេះ។

នៅពេលបុគ្គលណាមួយត្រូវបានបញ្ចូលឈ្មោះនៅក្នុងបញ្ជីរួចហើយ តុលាការត្រូវចេញដីកាបង្កកទ្រព្យសម្បត្តិនិងមូលនិធិដោយគ្មានបង្អង់។

តុលាការត្រូវដកបទបញ្ជា ប្រសិនបើពិនិត្យឃើញថា លែងមានមូលដ្ឋានសមហេតុផលសម្រាប់ដាក់បញ្ចូលក្នុងបញ្ជីទៀតហើយ។

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងដោយគ្មានបង្អង់ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់គតិយភាគី បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីក្រសួងយុត្តិធម៌អំពីបទបញ្ជាបង្កក

ក្នុងបញ្ជី និងការបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលដែលបានកំណត់នៅក្នុងបញ្ជីនោះ។

**មាត្រា១០.-**

ក្រសួងយុត្តិធម៌ត្រូវបោះផ្សាយនិងធ្វើបច្ចុប្បន្នកម្មលើគេហទំព័រសាធារណៈនូវការដាក់បញ្ចូលក្នុងបញ្ជី ឬដកចេញពីបញ្ជីតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ។

**មាត្រា១១.-**

ការបង្កកទ្រព្យសម្បត្តិនិងមូលនិធិតាមដីការបស់តុលាការមិនមានរយៈពេលកំណត់ទេ លើកលែងតែ ៖

(ក) បុគ្គលដែលបានកំណត់ក្នុងបញ្ជីបានឈ្នះបណ្តឹងក្នុងតុលាការ ឬ

(ខ) តតិយភាគី បានស្នើសុំដកឈ្មោះបុគ្គលដែលបានកំណត់ចេញពីបញ្ជី។

**ជំពូកទី៤**
**វិធានការរដ្ឋបាល**

**មាត្រា១២.-**

ជនជាតិកម្ពុជា ឬបុគ្គលណាដែលស្ថិតនៅក្នុងប្រទេសកម្ពុជាមិនត្រូវផ្តល់ដោយផ្ទាល់ ឬដោយប្រយោលនូវទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កកហើយទៅឲ្យ ឬទុកជាអត្ថប្រយោជន៍របស់បុគ្គល ឬអង្គការ ដែលបានកំណត់នៅក្នុងបញ្ជី។

**មាត្រា១៣.-**

ការសម្គាល់អត្តសញ្ញាណទ្រព្យសម្បត្តិនិងមូលនិធិដែលត្រូវបង្កកត្រូវធ្វើឡើងដោយតុលាការ។

**មាត្រា១៤.-**

បុគ្គលរាយការណ៍ត្រូវបញ្ជូនព័ត៌មានមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអំពីទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កកតាមដីកាតុលាការ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវបញ្ជូនបន្តព័ត៌មាននេះទៅក្រសួងយុត្តិធម៌។

បុគ្គល ឬនីតិបុគ្គលផ្សេងទៀត ក្រៅពីបុគ្គលរាយការណ៍ត្រូវបញ្ជូនព័ត៌មានទៅអាជ្ញាធរអាណាព្យាបាលរបស់ខ្លួនអំពីទ្រព្យសម្បត្តិនិងមូលនិធិដែលបានបង្កកតាមដីកាតុលាការ។ អាជ្ញាធរអាណាព្យាបាលត្រូវបញ្ជូនបន្តព័ត៌មាននេះទៅក្រសួងយុត្តិធម៌។

ព័ត៌មានទាំងនេះត្រូវរក្សាទុកជាការសម្ងាត់វិជ្ជាជីវៈ។

**មាត្រា១៥.-**

អាជ្ញាធរអាណាព្យាបាលត្រូវសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដាក់វិធានការរដ្ឋបាល ទៅលើបុគ្គលរាយការណ៍ ឬបុគ្គលផ្សេងទៀតដែលមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

វិធានការរដ្ឋបាលត្រូវអនុវត្តដូចខាងក្រោម៖

- ការព្រមាន
- ការស្តីបន្ទោស

- ការហាមឃាត់ ឬដាក់កំហិតមិនឲ្យធ្វើប្រតិបត្តិការណាមួយ ឬក្នុងរយៈពេលមួយតាមការកំណត់របស់អាជ្ញាធរអាណាព្យាបាល
- ការដកហូតអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ការដកហូតតំណែងមន្ត្រីឬនាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ និងបុគ្គលផ្សេងទៀតទាំងនោះ និង
- ការពិន័យជាប្រាក់ចាប់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ដល់២០០ ០០០ ០០០ (ពីររយលាន) រៀល។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ប្រធានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១០.៤២២ ហិកតា នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន គាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០០៥ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១០៩១ ខបប ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១០១ ខបប ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៦៨ ខបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១០.៤២២ ហិកតា ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

ក.ឃុំត្រែង

- កាត់ផ្ទៃដីទំហំ ៩៥៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិគីឡូ
- កាត់ផ្ទៃដីទំហំ ៣.០១៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិត្បារ
- កាត់ផ្ទៃដីទំហំ ២៥៨៣,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិជាមន្ត្រី
- កាត់ផ្ទៃដីទំហំ ៣.៧៣៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិជីសាង

ខ.ឃុំ ផ្លូវមាស

- កាត់ផ្ទៃដីទំហំ ១៣៤,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិជីប៉ាង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ៕

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

ក.ឃុំក្រែង

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិគីឡូ ភូមិភ្លាវ ភូមិជាមន្ត្រី និងភូមិដីសាង។

ខ.ឃុំ ផ្លូវមាស

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិដីប៉ាង ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៤.៦១៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៤.៥៩៦ ក្បាលដី ជូនប្រជាពលរដ្ឋ ២.៨៣៩ គ្រួសារ អចលនវត្ថុវត្ត ០១ ក្បាលដី និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ១៩ ក្បាលដី (ដីសាលារៀន ០៧ ក្បាលដី ដីវរៈសេនាតូចអន្តរាគមន៍លេខ៥២៣ ០១ ក្បាលដី ដីទួលបុរាណ ០៣ ក្បាលដី ដីសាលាឃុំ ០២ ក្បាលដី ដីមណ្ឌលសុខភាព ០១ ក្បាលដី ដីទីបញ្ជាការវរៈសេនាតូចវិស្វកម្ម ០១ ក្បាលដី ដីប៉ុស្តិ៍នគរបាល ០១ ក្បាលដី ដីប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី និងដីស្រះទឹក ០២ ក្បាលដី) នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលក្នុងនោះ ផ្តល់ជាកម្មសិទ្ធិលើក្បាលដីដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោមៈ

ក.ឃុំក្រែង

- សរុប ៧៦០ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៧៥៥ ក្បាលដី ជូនប្រជាពលរដ្ឋ ៥២៣ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៥ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីសាលាឃុំ ០១ ក្បាលដី ដីមណ្ឌលសុខភាព ០១ ក្បាលដី ដីទីបញ្ជាការវរៈសេនាតូចវិស្វកម្ម ០១ ក្បាលដី និងដីប៉ុស្តិ៍នគរបាល ០១ ក្បាលដី) នៅភូមិគីឡូ
- សរុប ១.២០៩ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.២០២ ក្បាលដី ជូនប្រជាពលរដ្ឋ ៧៦៧ គ្រួសារ អចលនវត្ថុវត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៦ ក្បាលដី (ដីសាលារៀន ០២ ក្បាលដី ដីវរៈសេនាតូចអន្តរាគមន៍លេខ៥២៣ ០១ ក្បាលដី និងដីទួលបុរាណ ០៣ ក្បាលដី) នៅភូមិភ្លាវ
- សរុប ១.២០១ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.១៩៧ ក្បាលដី ជូនប្រជាពលរដ្ឋ ៧៣៣ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៤ ក្បាលដី (ដីសាលារៀន ០២ ក្បាលដី និងដីស្រះទឹក ០២ ក្បាលដី) នៅភូមិជាមន្ត្រី

-សរុប ១.៣១២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.៣១០ ក្បាលដី ជូនប្រជាពលរដ្ឋ ៦៩៨ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីសាលារៀន) នៅភូមិដីសាង ។

ខ.ឃុំ ផ្លូវមាស

- សរុប ១៣៤ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១៣២ ក្បាលដី ជូនប្រជាពលរដ្ឋ ១១៨ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីសាលាឃុំ ០១ ក្បាលដី និងដីប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី) នៅភូមិដីប៉ាង ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## កាត់ដីទំហំ ១.២៣៣ ហិកតា ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០០៧ ឧបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១០២ ឧបប ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៦៦ ឧបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ១.២៣៣ ហិកតា ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- កាត់ផ្ទៃដីទំហំ ៥០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិបាស្រែ
- កាត់ផ្ទៃដីទំហំ ១៦៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិដូនបា
- កាត់ផ្ទៃដីទំហំ ៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិទួលលៀប
- កាត់ផ្ទៃដីទំហំ ៣៨២,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិខ្វែង
- កាត់ផ្ទៃដីទំហំ ៥៩៥,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិព្រៃប៉ែន

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៩៧២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៩៥៩ ក្បាលដី ជូនប្រជាពលរដ្ឋ ៦២៦ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ២២ ក្បាលដី (ដីសាលារៀន ០៥ ក្បាលដី ដីទួលរូមភូមិ ០១ ក្បាលដី ដីស្នាក់ការភូមិ ០១ ក្បាលដី ដីស្រះទឹក ០៦ ក្បាលដី ដីបឹង ០៧ក្បាលដី ដីសាលាឃុំ ០១ ក្បាលដី និងដីប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី) នៅឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលក្នុងនោះផ្តល់ជាកម្មសិទ្ធិលើក្បាលដី ៖

- សរុប ២១៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២០៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១២៤ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៨ ក្បាលដី (ដីសាលារៀន ០២ ក្បាលដី ដីទួលរូមភូមិ ០១ ក្បាលដី ដីស្រះទឹក ០១ ក្បាលដី ដីបឹង ០២ ក្បាលដី ដីសាលាឃុំ ០១ ក្បាលដី និងប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី) នៅភូមិដូនបា
- សរុប ៥៣ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៥២ ក្បាលដី ជូនប្រជាពលរដ្ឋ ៤៧ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីស្រះទឹក ០១ ក្បាលដី) នៅភូមិបាស្រែ
- សរុប ១៨៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១៨៣ ក្បាលដី ជូនប្រជាពលរដ្ឋ ១៥១ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីស្នាក់ការភូមិ ០១ ក្បាលដី និងដីបឹង ០១ ក្បាលដី) នៅភូមិទួលលៀប
- សរុប ២២០ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២១៨ ក្បាលដី ជូនប្រជាពលរដ្ឋ ១២២ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី និងដីស្រះទឹក ០១ ក្បាលដី ) នៅភូមិខ្វែង
- សរុប ២៩៥ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៨៧ ក្បាលដី ជូនប្រជាពលរដ្ឋ ១៩២ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៨ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីស្រះទឹក ០៣ ក្បាលដី និងដីបឹង ០៤ ក្បាលដី ) នៅភូមិព្រៃប៉ែន ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន និងជាឧត្តមមន្ត្រី |

| | |
|---|---|
| ៣- រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤- រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៥- រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧- រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៨- រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៩- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- រដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១- រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១២- រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១៥- រដ្ឋលេខាធិការ ក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៦- រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៧- រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨- រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៩- រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ២០- រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២១- រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២២- រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ២៣- រដ្ឋលេខាធិការ ក្រយសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ២៤- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ២៥- រដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៦- រដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៧- រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ២៨- រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៩- អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣០- អគ្គលេខាធិការរងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន | សមាជិក |
| ៣១- អនុប្រធានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិកម្ចាត់គ្រឿងញៀន | សមាជិក |
| ៣២- មេបញ្ជាការយោធភូមិភាគទី១ | សមាជិក |
| ៣៣- តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ៣៤- អភិបាលនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ៣៥- អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៣៦- អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |

៣៧- អភិបាលនៃគណៈអភិបាលខេត្តក្រចេះ សមាជិក។

**មាត្រា២.-**

សមាសភាពជាក់ស្តែងគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានភារកិច្ចដូចតទៅ៖

- សិក្សា-រៀបចំគម្រោង និងកម្មវិធីដែលត្រូវអភិវឌ្ឍន៍ដោយឡែក និងអភិវឌ្ឍន៍រួម នៅក្នុងតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ដើម្បីរកថវិកាមកអនុវត្តគម្រោង
- គិតគូរអំពីតុល្យភាពនៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណ និងអត្ថប្រយោជន៍ទាំងឡាយដែលប្រជាជននឹងត្រូវទទួលបាន
- សិក្សានិងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តគម្រោងនានា មកលើបរិស្ថាន វប្បធម៌ ប្រពៃណី-សាសនា និងទំនៀមទម្លាប់នៅក្នុងតំបន់ត្រីកោណ
- រៀបចំកម្មវិធីនិងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ និងបង្ក្រាបបទល្មើសឆ្លងដែន នៅក្នុងតំបន់ត្រីកោណ
- ទំនាក់ទំនង និងកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេសសម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធីនិងគម្រោងអាទិភាពទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត
- គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេច
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤.-**

គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្មលើលិខិតផ្លូវការ និងមានថវិកាដោយឡែកសម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងនិងស្ថាប័នពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់។

**មាត្រា៥.-**

គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានអនុគណៈកម្មការជំនាញចំនួនបួន ដូចខាងក្រោម៖

- អនុគណៈកម្មការការបរទេស និងសន្តិសុខ
- អនុគណៈកម្មការសេដ្ឋកិច្ច
- អនុគណៈកម្មការសង្គមកិច្ច និងបរិស្ថាន
- អនុគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត។

ប្រធាន អនុប្រធាន និងសមាជិក នៃអនុគណៈកម្មការជំនាញទាំងបួន ត្រូវតែងតាំងដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ផ្អែកតាមការចាត់បញ្ជូនពីក្រសួង-ស្ថាប័ននីមួយៗ។

អនុគណៈកម្មការទាំងបួននេះ ធ្វើការតាមការណែនាំរបស់គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងត្រូវរាយការណ៍ឱ្យបានទៀងទាត់តាមការកំណត់របស់ប្រធានគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម។

**មាត្រា៦.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ តែងតាំងដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការជាតិ។

**មាត្រា៧.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- សម្របសម្រួលដំណើរប្រព្រឹត្តទៅ របស់គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានជាអាទិ៍ រៀបចំផែនការការងារ

និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងកិច្ចប្រជុំពាក់ព័ន្ធ

- សម្របសម្រួល និងធ្វើការទំនាក់ទំនងការងារជាមួយបណ្តាក្រសួង-ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងអនុគណៈកម្មការជំនាញទាំងបួន
- សម្របសម្រួលជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិនានា
- បំពេញការងារដទៃទៀត តាមការណែនាំរបស់គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ដូចមាត្រា៩
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ៦៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សម្រេច

**មាត្រា ១ :**

ត្រូវបានតែងតាំងលោក **ឆូច សុធីរា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីទី ២ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសជប៉ុន ជំនួសលោក **អ៊ុក ចាន់ដារ៉ា**។

**មាត្រា ២ :**

ត្រូវបាននិរាករណ៍អនុក្រឹត្យ លេខ ៩០ អ.ន.ក្រ.តត ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់។

**មាត្រា ៣ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

### មាត្រា ១ .-

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តមណ្ឌលគិរីចំនួន ១០ នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក- មេដាយមាសការងារ ៖**

| | |
|---|---|
| ១-លោក **ឆាង ចណ្ណា:** | ប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី |
| ២-លោក **ទាវ ស៊ានហ៊ាន់** | ប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី |
| ៣-លោក **ហោ សុខជា** | មន្ត្រីសាលាខេត្តមណ្ឌលគិរី |
| ៤-លោក **ប្រាក់ សំណាង** | ប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី |

**ខ- មេដាយប្រាក់ការងារ ៖**

| | |
|---|---|
| ១-លោក **ឃិន ចាន់ថន** | មន្ត្រីសាលាខេត្តមណ្ឌលគិរី |
| ២-លោក **ផុន រឿ** | អនុប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី |

៣-លោកស្រី **ចែម ផល** អនុប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី

**គ- មេធាវីសំរឹទ្ធករងារ ៖**

១-លោក **អ៊ិត មុនិន្ទ** មន្ត្រីសាលាខេត្តមណ្ឌលគិរី

២-លោកស្រី **ចាន់ ស៊ីហាម៉ានី** មន្ត្រីសាលាខេត្តមណ្ឌលគិរី

៣-លោកស្រី **កែវ ដាលីស** អនុប្រធានការិយាល័យសាលាខេត្តមណ្ឌលគិរី

**មាត្រា ២ .-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ... ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ១ និងមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៩៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

**សម្រេច**

**មាត្រា ១.-** បំពាក់ មេដាយមាសការងារ ចំនួន ១០គ្រឿង ជូនមន្ត្រីរាជការ ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាងអភិវឌ្ឍន៍ មូលដ្ឋាន តាមបណ្តា ភូមិ ឃុំនានា ក្នុងស្រុក-ក្រុង នៃខេត្តព្រះសីហនុ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | ចោង សារី | មន្ត្រីផ្នែកសណ្ឋាគារមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ |
| ២-លោក | ជួន ម៉ុនចេង | អត្តលេខ ៥៩៩២៧ |
| ៣-លោក | មាស សំអាត | អត្តលេខ ៥៩៩១៣ |
| ៤-កញ្ញា | ម៉ឿន សំអាត | សប្បុរសជន |
| ៥-កញ្ញា | ម៉ឿន សុគន្ធា | សប្បុរសជន |
| ៦-លោក | ម៉ឿន បូរាណា | សប្បុរសជន |
| ៧-លោក | ម៉ឿន ពេជ្រតិរុណា | សប្បុរសជន |
| ៨-លោក | ស្រ៊ុន ម៉ិនថាត | សប្បុរសជន |
| ៩-លោក | សន រិទ្ធា | សប្បុរសជន |
| ១០-លោក | ចិន សុផាត | សប្បុរសជន |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

### សម្រេច

**មាត្រា ១.**-បំពាក់ មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ ចំនួន ១៧គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាងអភិវឌ្ឍន៍ មូលដ្ឋាន តាមបណ្តា ភូមិ ឃុំនានា ក្នុងស្រុក-ក្រុង នៃខេត្តព្រះសីហនុ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | ចិន សឿន | សប្បុរសជន |
| ២-អ្នកគ្រូ | គុណា ដាណា | សប្បុរសជន |
| ៣-លោកគ្រូ | ហុក ឆោយ | សប្បុរសជន |
| ៤-លោក | តែ ប៉ហុង | សប្បុរសជន |
| ៥-កញ្ញា | មុំ សុរតន៍ម៉ូណា | សប្បុរសជន |
| ៦-លោកស្រី | ហ្លួយ ហ៊ុយឆេង | សប្បុរសជន |
| ៧-លោកស្រី | អ៊ែត ដាឡូងធីតាវី | សប្បុរសជន |
| ៨-លោក | លន់ យ៉េង | សប្បុរសជន |
| ៩-កញ្ញា | ថេ សុខា | សប្បុរសជន |
| ១០-លោក | លី វិសាល | សប្បុរសជន |
| ១១-លោក | ស៊ឹម វិច្ឆិកា | សប្បុរសជន |
| ១២-លោក | ញៀប ចាន់មករា | សប្បុរសជន |
| ១៣-កញ្ញា | សុវណ្ណ គន្ធារី | សប្បុរសជន |
| ១៤-លោក | ចាន់ សេរីរដ្ឋា | សប្បុរសជន |
| ១៥-លោក | សៅ សុវណ្ណារិទ្ធ | សប្បុរសជន |

១៦-លោក **លិម ជាន** សប្បុរសជន
១៧-លោក **សុគ សាន** សប្បុរសជន

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ នៃសមាសភាពក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៤ ស្តីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ឱ្យស្ថិតក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១២ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលភារកិច្ច និងតែងតាំងមន្ត្រីនៃសមាសភាពក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្នុងអាណត្តិទី៥ ដែលមានរាយនាមដូចខាងក្រោម ៖

១. ឯកឧត្តម សឹម ណារ៉ា អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាប្រធានក្រុមប្រឹក្សាភិបាល

២. ឯកឧត្តម ម៉ី វ៉ាន់ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកក្រុមប្រឹក្សាភិបាល

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៩៥ . អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន០២រូប:

១-លោក **លឹម ម៉េងហួរ** មានឋានៈស្មើ អគ្គនាយករង

២-លោក **សួន ឈឿង** មានឋានៈស្មើ អគ្គនាយករង

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.—**

ត្រូវបានតែងតាំងមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម ៖

១- លោកស្រី **ខ៊ិត ម៉ូទីឡែន** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

២- លោក **ញ៉ែម សុវណ្ណា** ជាប្រធាននាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន ។

**មាត្រា២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩៧ អនក្រ.តត**

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តែងតាំងជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៣ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ៖

| | | |
|---|---|---|
| ១- លោកវរសេនីយ៍ឯក | **សួស សុខជាវ៉ា** | អត្តលេខ ០៣៣១២ |
| ២- លោកវរសេនីយ៍ឯក | **ស៊ឹម សំអាត** | អត្តលេខ ១២២០៩ |
| ៣- លោកវរសេនីយ៍ទោ | **កើត ជាវ៉ាស៊ី** | អត្តលេខ ០៨៩៩៩ ។ |

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.....១៨៤ អនក្រ.បក

# អនុក្រឹត្យ
